អេស៊ីលីដា ACLEDA BANK

# ទម្រង់វិញ្ញាបនបត្រប្រាក់បញ្ញើ
## Certificate Of Deposit Form

សូមបំពេញបែបបទខាងក្រោមនេះឲ្យបានត្រឹមត្រូវ និងច្បាស់លាស់
*Please fill in this application properly.*

○ **បើកប្រើប្រាស់/Opening** ○ **បញ្ចប់/Early redemption** ○ **បន្ត/Rollover** ○ **មិនបន្ត/Stop Rollover**

**ឈ្មោះគណនី:** Account name: ______ **លេខគណនីប្រភព:** Source account No.: ______

ប្រភេទគណនី: Account type: ○ គណនីមានកាលកំណត់ចំណូលខ្ពស់ High Income Fixed Deposit ○ គណនីមានកាលកំណត់កំណើនខ្ពស់ High Growth Fixed Deposit ○ គណនីមានកាលកំណត់រយៈពេលវែង Long Term Fixed Deposit

ប្រភេទរូបិយប័ណ្ណ: Currency type: ○ ប្រាក់រៀល Riel ○ ប្រាក់ដុល្លារ Dollar ○ ប្រាក់បាត Baht ○ ផ្សេងៗ: Other ______

**ចំនួនទឹកប្រាក់បញ្ញើ:** Deposit amount: ______ រយៈពេលដាក់ប្រាក់បញ្ញើ: Term of deposit: ○ ____ ខែ Months ○ ____ ឆ្នាំ Years

លេខកិច្ចសន្យា: Contract number: ______ ថ្ងៃប្រសិទ្ធភាព: Effective date: dd | mm | yy

បន្តជាស្វ័យប្រវត្តិ? Automatic Rollover?: ○ បន្តទាំងប្រាក់ដើម និងការប្រាក់ Principal and interest ○ បន្តតែប្រាក់ដើម Principal only ○ មិនបន្ត No Rollover

(បន្តរយៈពេលប៉ុន្មានដង?/How many terms?: ______ )

មូលហេតុសុំបញ្ចប់ ឬមិនបន្ត ឬបន្តវិញ្ញាបនបត្រប្រាក់បញ្ញើ:/Reason for Closing or Stop Rollover or Rollover Certificate of Deposit:

..................................................

..................................................

ការចុះហត្ថលេខា ឬផ្តិតមេដៃលើទម្រង់នេះគឺមានន័យថា ខ្ញុំ/យើងបានអាន យល់ច្បាស់ និងយល់ព្រមនូវរាល់លក្ខខណ្ឌ និងខចែងដែលមាននៅទំព័រខាងក្រោយ ។ ខ្ញុំ/យើងទទួលខុសត្រូវនូវរាល់ព័ត៌មានដែលបានផ្តល់ឲ្យធនាគារ ។
By signing or thumbprint this application form, I/We have read, understood and agreed with all of the terms and conditions on the reverse of this form. I/We take full responsibilities for the information provided.

ហត្ថលេខា ឬស្នាមមេដៃអតិថិជន
Customer's signature or thumbprint

កាលបរិច្ឆេទ: Date: dd | mm | yy

### សម្រាប់ធនាគារ/Bank use only

**Inputted by/Prepared by**
Name: ......
Signature

**Verified by**
Name: ......
Signature

**Approved by**
Name: ......
Signature
Date: dd | mm | yy

# លក្ខខណ្ឌទូទៅក្នុងការប្រើប្រាស់គណនីមានកាលកំណត់ ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី TERMS AND CONDITIONS OF FIXED DEPOSITS

១ ប្រាក់បញ្ញើមានកាលកំណត់ គឺជាកិច្ចសន្យារវាងលោកអ្នក និងធនាគារ អេស៊ីលីដា ភីអិលស៊ី ស្តីពីការដាក់ប្រាក់បញ្ញើក្នុងអំឡុងពេលកំណត់មួយជាក់លាក់ នៅតាមការិយាល័យធនាគារ ឬសេវាធនាគារអេឡិចត្រូនិក និងឌីជីថល ដើម្បីទទួលបានការប្រាក់ខ្ពស់ និងមានសុវត្ថិភាព ។

២ លោកអ្នកអាចជ្រើសរើសលក្ខខណ្ឌដាក់ប្រាក់បញ្ញើមានកាលកំណត់កំណើនខ្ពស់ ប្រាក់បញ្ញើមានកាលកំណត់ចំណូលខ្ពស់ និងប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង និងបន្តកិច្ចសន្យាដោយស្វ័យប្រវត្តិបាន ។ លោកអ្នកនឹងទទួលបានវិញ្ញាបនបត្រប្រាក់បញ្ញើ ឬវិញ្ញាបនបត្រអេឡិច-ត្រូនិកជាភស្តុតាង បន្ទាប់ពីបានព្រមព្រៀងលើពាក្យសុំវិញ្ញាបនបត្រប្រាក់បញ្ញើ និងដាក់ប្រាក់ចូលក្នុងគណនីរួចរាល់ ។

៣ លោកអ្នកអាចដកប្រាក់បញ្ញើនៅតាមបញ្ជរបេឡា ឬតាមរយៈម៉ាស៊ីនស្វ័យប្រវត្តិរបស់ធនាគារ អេស៊ីលីដាបាន ចាប់ពីកាលបរិច្ឆេទបញ្ចប់នៅក្នុងវិញ្ញាបនបត្រប្រាក់បញ្ញើ ឬដកប្រាក់ដើមមុនកាលកំណត់ដូចខាងក្រោម៖

៣.១ ការដកប្រាក់បញ្ញើតាមកាលបរិច្ឆេទបញ្ចប់

- **ប្រាក់បញ្ញើមានកាលកំណត់កំណើនខ្ពស់:** ប្រាក់ដើម និងការប្រាក់ដកបាននៅពេលចប់កិច្ចសន្យា ។
- **ប្រាក់បញ្ញើមានកាលកំណត់ចំណូលខ្ពស់:** ការប្រាក់ដកបានរៀងរាល់ខែ ប្រាក់ដើមដកបាននៅពេលចប់កិច្ចសន្យា ។
- **ប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង:** ការប្រាក់ដកបានរៀងរាល់បីខែម្តង ប្រាក់ដើមដកបាននៅពេលចប់កិច្ចសន្យា ។

៣.២ ការដកប្រាក់ដើមមុនកាលកំណត់

លោកអ្នក អាចបញ្ចប់កិច្ចសន្យាប្រាក់បញ្ញើមុនកាលកំណត់គ្រប់ប្រភេទ ដើម្បីដកប្រាក់ដើមមុនកាលកំណត់បាន និងត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

៣.២.១ ចំពោះលោកអ្នក ជាតំណាងគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុត្រូវជូនដំណឹងមុនយ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ តាមការដាក់ពាក្យស្នើសុំបញ្ចប់ ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈលិខិតផ្លូវការ ឬសេវាបញ្ជាតាម E-mail/Fax មកធនាគារ និងភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ដោយមិនទទួលបានការប្រាក់ឡើយ ហើយត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដាវិញ ក្នុងករណីបានទទួលការប្រាក់ប្រចាំខែចំពោះប្រាក់បញ្ញើមានកាលកំណត់ចំណូលខ្ពស់ និងបានទទួលការប្រាក់ប្រចាំត្រីមាសចំពោះ ប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែងរួចហើយ ។

៣.២.២ ចំពោះលោកអ្នកជាតំណាងក្រុមហ៊ុន/ស្ថាប័ន ក្រៅពីគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ត្រូវជូនដំណឹងមុនយ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ តាមការដាក់ពាក្យស្នើសុំបញ្ចប់ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈលិខិតផ្លូវការ ឬសេវាបញ្ជាតាម E-mail/Fax មកធនាគារ ដោយមិនតម្រូវឲ្យភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ឡើយនិងទទួលបានការប្រាក់តាមអត្រានៃគណនីបញ្ញើសំចៃលើចំនួនទឹកប្រាក់បញ្ញើដែលស្នើសុំដកមុនកាលកំណត់។ចំពោះលោកអ្នកស្រីដាក់ប្រាក់បញ្ញើមានកាលកំណត់ចំណូលខ្ពស់ និងប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង ប្រសិនបើក្នុងអំឡុងពេលកន្លងមក បានទទួលការប្រាក់ប្រចាំខែ និងប្រចាំត្រីមាសរួចហើយ ត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដា ភីអិលស៊ី វិញ ។

៣.២.៣ ចំពោះលោក-អ្នក ជាឯកត្តជន អាចបញ្ចប់កិច្ចសន្យាប្រាក់បញ្ញើមុនកាលកំណត់ ដោយមិនតម្រូវឲ្យភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ឡើយ ។ ការប្រាក់នឹងទទួលបានតាមអត្រាការប្រាក់នៃគណនីបញ្ញើសំចៃ លើចំនួនទឹកប្រាក់បញ្ញើដែលស្នើសុំដកមុនកាលកំណត់ ចំពោះប្រាក់បញ្ញើមានកាលកំណត់កំណើនខ្ពស់ និងប្រាក់បញ្ញើមានកាលកំណត់ចំណូលខ្ពស់ ប៉ុន្តែការប្រាក់ដែលអតិថិជនទទួលបានប្រចាំខែ រួចហើយ នឹងត្រូវកាត់កងជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដា ភីអិលស៊ីវិញ។ ចំពោះប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង ត្រូវជូនដំណឹងមុនយ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ តាមការដាក់ពាក្យស្នើសុំបញ្ចប់ ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈលិខិតផ្លូវការ ឬសេវាបញ្ជាតាម E-mail/Fax មកធនាគារ ដើម្បីទទួលបានការប្រាក់តាមអត្រានៃគណនីបញ្ញើសំចៃធម្មតា បើមិនដូច្នោះទេ ការប្រាក់មិនត្រូវបានផ្តល់ជូនឡើយ ហើយប្រសិនបើក្នុងអំឡុងពេលកន្លងមក បានទទួលការប្រាក់ប្រចាំត្រីមាសរួចហើយ ត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដាវិញ ។

៤ ចំណូលការប្រាក់របស់លោកអ្នក ត្រូវជាប់ពន្ធស្របតាមប្រកាស ស្តីពីពន្ធលើប្រាក់ចំណេញ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៥ អត្រាការប្រាក់ដែលបានព្រមព្រៀងរួចហើយមិនអនុញ្ញាតឲ្យកែប្រែឬផ្លាស់ប្តូរដោយពុំមានការយល់ព្រមពីភាគីណាមួយឡើយ នៅពេលដែលកិច្ចសន្យាដាក់ប្រាក់បញ្ញើមានកាលកំណត់មិនទាន់បញ្ចប់ ។

៦ ការបន្តកិច្ចសន្យាស្វ័យប្រវត្តិកើតឡើងនៅពេលដែលលោកអ្នកបានស្នើសុំដាក់ប្រាក់បញ្ញើបន្តមួយវគ្គទៀត ឬច្រើនវគ្គបន្តបន្ទាប់គ្នាដោយមិនមានការផ្លាស់ប្តូរលេខកិច្ចសន្យាថ្មី ។ ការបន្តបែបនេះ គឺអាស្រ័យទៅតាមការបង្គាប់របស់លោកអ្នក តាមរយៈការផ្តល់ព័ត៌មាននៅពេលបើកគណនី ឬជូនដំណឹងនៅពេលណាមួយក្នុងអំឡុងពេលនៃកិច្ចសន្យា ឬយ៉ាងតិចបំផុត ០២ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃបញ្ចប់កិច្ចសន្យា ។

៧ នៅពេលលោកអ្នក ជ្រើសរើសលក្ខខណ្ឌបន្តដោយស្វ័យប្រវត្តិ មានន័យថា លោកអ្នកព្រមព្រៀងបន្តផ្ញើប្រាក់ជាមួយធនាគារអេស៊ីលីដា ភីអិលស៊ីតទៅទៀត ដែលមានប្រាក់ដើម ឬប្រាក់ដើមរួមទាំងការប្រាក់ដែលបានទទួល និងរយៈពេលផ្ញើនៅរក្សាដូចកិច្ចសន្យាដែលបានព្រមព្រៀងពីដំបូងដដែល លើកលែងតែអត្រាការប្រាក់ត្រូវអនុវត្តដូចខាងក្រោម៖

- គិតជូនតាមអត្រាការប្រាក់ធម្មតាដែលធនាគារ អេស៊ីលីដា ដាក់ឲ្យប្រើ-ប្រាស់ជាផ្លូវការចុងក្រោយបង្អស់ ។
- ចំពោះលោកអ្នក ដែលមានកិច្ចព្រមព្រៀងផ្តល់អត្រាការប្រាក់ពិសេសមិនអនុញ្ញាតឲ្យជ្រើសរើសលក្ខខណ្ឌបន្តជាស្វ័យប្រវត្តិឡើយ ។ ករណីមានតម្រូវការដាក់ប្រាក់បញ្ញើបន្តទៀត គឺត្រូវគិតការប្រាក់តាមអត្រាធម្មតាវិញ ។

៨ ករណីលោកអ្នកស្នើសុំវិញ្ញាបនបត្រប្រាក់បញ្ញើថ្មីជំនួសវិញ្ញាបនបត្រប្រាក់បញ្ញើចាស់ដែលបានបាត់ ឬខូច លោកអ្នកត្រូវបង់ថ្លៃសេវាតាមការកំណត់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

៩ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានសិទ្ធិពេញលេញក្នុងការបដិសេធមិនទទួល ឬមិនបន្តកិច្ចសន្យា ឬបញ្ឈប់កិច្ចសន្យា មុនពេលកំណត់ ប្រសិនបើលោកអ្នក ត្រូវបានរកឃើញថាមិនគោរពតាមគ្រប់ “ខ” ចែងដែលមានរៀបរាប់នៅក្នុងលក្ខខណ្ឌទូទៅ ឬមានភស្តុតាងបញ្ជាក់ថា៖

- មិនបានអនុវត្តទៅតាមគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធនឹងការប្រតិបត្តិគណនី ដូចជាច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។
- មានការជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយបុគ្គល ឬអង្គភាពដែលត្រូវបានហាមឃាត់ ក្នុងគោលបំណងបម្រើប្រយោជន៍ដល់សកម្មភាពល្មើសច្បាប់ និង/ឬសកម្មភាពភេរវកម្ម ។

១០ សម្រាប់តម្រូវការប្រើប្រាស់សេវាធនាគារ អេស៊ីលីដា ភីអិលស៊ី និងព័ត៌មានផ្សេងៗទៀត សូមលោកអ្នក ទំនាក់ទំនងការិយាល័យទំនាក់ទំនងអតិថិជន ២៤ម៉ោង តាមរយៈទូរស័ព្ទលេខ: ០២៣ ៩៩៤ ៤៤៤
០១៥ ៩៩៩ ២៣៣ ឬ E-mail: inquiry@acledabank.com.kh

1 Term Deposit is an agreement between ACLEDA Bank Plc. and customers who deposit at the bank branch or electronic and digital banking services within a certain period of time to earn high interest rate and safety.

2 Customer has an option deposit cash as Hi-Growth Term Deposit, Hi-Income Term Deposit, and Long Term Deposit and choose the renewal automatically. The Customers will receive a Certificate or E-Certificate of Term Deposit as proof after completely deposit into the bank account.

3 Customer enables to process of cash withdrawal on the maturity date or prematurity date for cash of principle at bank counter or through ACLEDA ATMs:

3.1 Cash withdrawal on the maturity date

- **Hi-Growth Term Deposit:** principle and interest can be withdrawal on the maturity date.
- **Hi-Income Term Deposit:** interest can be withdrawal every month and principle can be withdrawal on the maturity date.
- **Long Term Deposit:** interest can be withdrawal every three months and principle can be withdrawal on the maturity date.

3.2 Cash of principle withdrawal on prematurity date

Customer can terminate the deposit agreement before maturity date and shall apply to the following conditions as below:

3.2.1 Customer who is a representative of a bank or microfinance Institution must inform to ACLEDA Bank Plc. at least 30 business days in advance by completed the terminate certificate of deposit form or written in notice via official letter or by Service Order via E-mail/Fax from the authorized person and attach with certificate of Term deposit. The interest is not provided and customers will have to settle the principle to the bank if they have already received monthly interest for Hi-Income Term Deposit and quarterly interest for Long Term Deposit.

3.2.2 Customer who is a representative of a company/entity beside bank or microfinance institution must inform to ACLEDA Bank Plc. at least 30 business days in advance by completed the terminate certificate of deposit form or written in notice via official letter or by Service Order via E-mail/Fax without having to attach with certificate of Term deposit if customer requests for cash of principle withdrawal on the prematurity date. The interest will be provided as savings account on the principal amount requested. If they have already received monthly interest for Hi-Income Term Deposit and have already received quarterly interest for Long Term Deposit, they will have to settle the cash of principal to the bank.

3.2.3 Customer who is an individual can end the contract before maturity date without having to attach with certificate of Term deposit if customer requests for cash of principle withdrawal on the prematurity date. The interest will be provided as savings account on the principal amount requested for early withdrawal for Hi-Growth Term Deposit and Hi-Income Term Deposit, the customer will have to settle the cash of principal to the bank if they have already received monthly interest. Exemption for Long Term Deposit, the customer must inform to ACLEDA Bank Plc. at least 30 business days in advance by completed the terminate certificate of deposit form or written in notice via official letter or by Service Order via E-mail/Fax to receive interest rate as savings account, otherwise interest will be not provided. If customers have already received quarterly interest, they will have to settle the cash of principal to the bank.

4 Customer interest income is an imposed tax in accordance with the Prakas on Profit Tax of the Ministry of Economy and Finance.

5 The interest rate of Term Deposit that was already agreed will not allow to be modified or changed without the consent of either parties when the deposit agreement has not terminated.

6 Automatic renewal of Term Deposit occurs when customer requests for one or more than one consecutive terms without changing a new agreement number. Such renewal depends on customer orders by providing information when opening the bank account or notifying at any time during the contract period or at least two business days before the end of contract.

7 When customers choose the automatic renewal terms, which means they agree to continue saving money at the bank for cash of principal or cash of principal with received interest and period of Term Deposit will keep as agreed in the first agreement. The interest exemption shall apply to the following conditions:

- The interest is calculated as normal following by the latest official standard rate of ACLEDA Bank Plc.
- A special interest rate agreement holding by customer is not allowed to choose the automatic renewal terms but in case there is a need for further deposit, the interest will be calculated as normal rate.

8 If customer requests for a new certificate of Term Deposit to replace the old one that is lost or damaged, customer will pay for service fee determined by ACLEDA Bank Plc.

9 The bank has full right to refuse, reject, non-renewable or terminate the agreement before maturity date, if customer is not complied with general terms and conditions which proof that:

- Customers do not comply with various laws and provisions related to account transactions, such as anti-money laundering and financing of terrorism.
- Customers are directly or indirectly associated with a prohibited person or entity for the purpose of serving illegal activities and/or terrorist activities.

10 For banking services or other information, please visit your nearest ACLEDA Bank branch or call our 24/7 Call Centre: 023 994 444 / 015 999 233 or E-mail: inquiry@acledabank.com.kh